# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីសម្រេចកែសម្រួលលើកទី៣
## លើឯកសារអាជ្ញាប័ណ្ណលេខ ១០១ ឯអ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤
## ជាមួយសេចក្តីសម្រេចកែសម្រួលលើកទី២ លេខ១០១សរ_០៦_អអក
## ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦
## សម្រាប់លោក ឈិន សុង
## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ១០១ឯអ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤

-យោងពាក្យស្នើសុំពង្រីកតំបន់ចែកចាយអគ្គិសនីរបស់លោក ឈិន សុង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៧ ដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី១២៣ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨

## សម្រេច

### ប្រការ១

កែសម្រួលអាជ្ញាប័ណ្ណលេខ ១០១ អ ដែលបានផ្តល់ឱ្យលោក ឈិន សុង ដោយអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយអគ្គិសនីទៅតាមបណ្តោយផ្លូវជាតិលេខ៣ ពីព្រំប្រទល់មានស្រោប់ទៅដល់ស្ពានស្លាគូ ស្ថិតនៅឃុំបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ ដើម្បីអនុញ្ញាតឱ្យលោក ឈិន សុង ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់បន្ថែមដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុង ឧបសម្ព័ន្ធទី១ ។

### ប្រការ២

ឧបសម្ព័ន្ធទី១ ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ១០១ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

**ប្រការ៣**

សេចក្តីសម្រេចនេះនិង ឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ១០១ ឯអ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ១០១ឯអ និង ខ្លឹមសារដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាម ទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ១០១ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ១០១ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី១

## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## លើកទី១២៣ នាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨

១- តំបន់អនុញ្ញាតឱ្យលោក ឈិន សុង ធ្វើសេវាកម្មចែកចាយនិងផ្គត់ផ្គង់អគ្គិសនី គឺ នៅឃុំបឹងត្រាញ់ខាងជើង និងបឹងត្រាញ់ខាងត្បូង ស្រុកសំរោង ខេត្តតាកែវ និងឃុំពោធិ៍អង្គ្រង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។

២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ “ផែនទីកំណត់ព្រំប្រទល់លេខ 101 LD- Map-Chhin Song-Revision 3 2008 ” ដែលភ្ជាប់មកជាមួយ ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោក ឈិន សុង មានបំណងស្នើសុំពង្រីកឬបន្ថែមតំបន់ចែកចាយថែមទៀតពេលនោះលោក ឈិន សុង ត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។